# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីពាក្យខ្មែរមួយឃ្លាពោលដាស់តឿនកូនចៅថា
## ប្រយ័ត្នខ្លាចាស់ចាំសីល

**web site: hoksavann.org**

ថ្ងៃទី៩ កក្កដា ២០០៥

ពាក្យថា ខ្លាចាស់ចាំសីលនេះ មាននិទានក្នុងរឿងមួយនៅក្នុងសៀវភៅស្រីហិតោបទេស ។ រឿងនោះដំណាលថា មានខ្លាមួយស្គមអត់ចំណី ក្លែងខ្លួនធ្វើជាអ្នករក្សាសីល ពុំសម្លាប់សត្វតទៅទៀត ដោយបំណងបោកបញ្ឆោតបុរសម្នាក់ ដើម្បីយកជាចំណី បានជាចាស់បូរាណពោលថា ប្រយ័ត្នខ្លាចាស់ចាំសីល ដូចមានដំណើររឿងដោយសេចក្ដីសង្ខេបថា មានខ្លាចាស់មួយអត់ចំណីមានកាយស្គាំងស្គមហេវអស់កម្លាំងដើរទៅឆ្ងាយពុំរួច ពុំអាចរត់ទៅចាប់សត្វឬមនុស្សស៊ីបាន ក៏ប្រើល្បិចធ្វើជាអ្នករក្សាសីល ។ ថ្ងៃមួយ ឃើញមនុស្សម្នាក់ដើរមកពីចម្ងាយ ខ្លាធ្វើជាមុជទឹកលាងបាប ។ លុះបុរសនោះដើរមកជិត ខ្លាបានលើកកងមាសមកបង្ហាញហើយស្រែកហៅបុរសនោះឲ្យចូលមកយក ។ បុរសនោះឃើញក៏មានសេចក្ដីលោភចង់បាន តែមានសេចក្ដីភ័យខ្លាច ខ្លាដឹងហើយក៏និយាយឲ្យទុកចិត្តថា ខ្ញុំកាលនៅពីក្មេងបានចាប់សត្វនិងមនុស្សស៊ីជាអាហារពិតមែន ដែលអំពើដែលខ្ញុំធ្វើអាក្រក់នេះ កូនចៅខ្ញុំបានស្លាប់អស់ តាបសឥសីម្នាក់បានប្រៀបប្រដៅខ្ញុំ ឲ្យឈប់ប្រព្រឹត្តធ្វើដូច្នេះតទៅទៀត ចាប់ពីពេលនោះមក ខ្ញុំបានធ្វើទានរក្សាសីលចំរើនមេត្តាភាវនាមុជទឹកលាងបាបរាល់ពេល ខ្ញុំកាន់ចាស់ហើយខ្ញុំឈប់ធ្វើបាបហើយ ។ បន្ទាប់មកខ្លាបានលើកយកធម៌អាថ៌ខ្លះមកពន្យល់រហូតដល់បុរសនោះស្លាប់គំនិតជឿថា ខ្លាចាស់កាន់សីលពិតមែន ។ ពេលដឹងថាបុរសនោះជឿហើយ ទើបខ្លានិយាយថា មុននឹងមកទទួលយកកងមាសពីខ្ញុំ ចូរអ្នកមុជទឹកលាងបាបសិន ព្រោះថាអ្នកឲ្យបរិសុទ្ធ អ្នកទទួលក៏បរិសុទ្ធ ទើបទាន់នោះមានផលច្រើន ។ ការពិតវិញ ការដែលខ្លាឲ្យបុរសនោះ ចុះទៅក្នុងទឹក ដោយមានគោលបំណង២យ៉ាងគឺ ៖ ១- ដើម្បីឲ្យបុ-

រសនោះទុកចិត្តកាន់តែខ្លាំងឡើងថែមទៀត ។ ២- បើខាំស៊ីពេលដែលបុរសនោះមកយកកងមាស ខ្លាចក្រែងបុរសនោះគេចខ្លួនរួច ពេលដែលខ្លួនខាំត្របាក់ស៊ី ត្រូវទុកឲ្យបុរសនោះជាប់ជុងក្នុងភក់ ពេលដែលចុះទឹកទៅ ខ្លួននឹងខាំស៊ីបានដោយស្រួល ។ បុរសនោះ ក៏ចុះទៅក្នុងទឹកជាប់ផុងក្នុងភក់រើខ្លួនពុំរួច ខ្លាឃើញហើយ ក៏ធ្វើជានិយាយថា អ៊ូអ្នកឯងជាប់ផុង មិនអីទេចាំខ្ញុំទៅជួយ ដោយខ្លាចផុងដែរ ខ្លាក៏ដើរទៅសន្សឹមៗ ដល់ភ្លាមក៏ខាំបុរសនោះជាប់ ដោយដឹងថាខ្លួននឹងត្រូវស្លាប់ បុរសនោះក៏យំអាណិតខ្លួន ដោយសារតែមានសេចក្តីលោភ ខ្វះការពិចារណាឲ្យយល់ហេតុផលពិតចាញ់ឧបាយកលរបស់សត្វខ្លា ខ្លាក៏ទំពារស៊ីបុរសនោះភ្លាមតាមសេចក្តីស្រេកឃ្លានរបស់ខ្លួន ដែលអត់ចំណីជាយូរថ្ងៃមកហើយ ។ បុរសនោះក៏ដល់នូវមរណភាពទៅ ។

រឿងនេះ បានជាឧទាហរណ៍សំខាន់ណាស់ សំរាប់ទាញការប្រុងប្រយ័ត្នរបស់ជនជាតិខ្មែរ ទៅលើបញ្ហាគ្រួសារ បញ្ហាស្រុកទេស កុំឲ្យចាញ់ឧបាយកលបរទេសទុច្ចរិត ដោយការពុំបានពិចារណាឲ្យដឹងការពិត នាំឲ្យមានគ្រោះថ្នាក់ដល់ជាតិខ្លួន ដោយសារតែជឿអាការៈទន់ភ្លន់និងសំដីផ្អែមល្ហែមខាងក្រៅ ។ ធម្មតាជាតិជាសត្វខ្លាធ្លាប់ស៊ីសាច់សត្វសាច់មនុស្ស ពុំអាចលះបង់នូវអំពើនេះបានឡើយ ។ យ៉ាងណាមិញ ជនពាលធ្លាប់ធ្វើអំពើបាបពីដើមមកហើយ គេនៅតែពុំលះបង់អំពើបាបនោះឡើយ ។ នៅសម័យពុទ្ធកាល គ្រូសញ្ជ័យ ទោះបីកូនសិស្ស មានសេរីបុត្រជាដើម រត់ចោលមកបួសក្នុងសំណាក់ព្រះពុទ្ធជាម្ចាស់ក៏ដោយ ទោះបីដឹងថា លទ្ធិរបស់ខ្លួនជាលទ្ធិខុស ក្នុងដំណើរទៅកាន់ការរំដោះទុក្ខក៏ដោយ ក៏លោកនៅតែមានៈប្រកាន់លទ្ធិរបស់លោកដដែល ។ ការប្រកាន់ទិដ្ឋិនិងមានៈនេះមានកម្លាំងខ្លាំងក្លាណាស់ លោកឈឺចាប់ក្នុងចិត្តរហូតធ្លាក់ឈាមស្លាប់ មិនព្រមលះទិដ្ឋិការប្រកាន់ខុសនោះ រួចមកបួសក្នុងសំណាក់ព្រះពុទ្ធឡើយ ។ ទំនងដូចគ្នានេះ ពួកមេឃាតករខ្មែរក្រហម ពុំមែនបំរើមនោគមវិជ្ជាកុម្មុយនិស្ត សុខចិត្តស្លាប់ខ្លួនឯង ពុំបៀតបៀនអ្នកដទៃដូចគ្រូសញ្ជ័យទេ តែពួកនេះបានឃោសនាដោយប្រើល្បិចបោកបញ្ឆោតប្រជាពលរដ្ឋខ្មែរឲ្យជឿ ដូចខ្លាចាស់ចាំសីល ទីបំផុតប្រជាពលរដ្ឋខ្មែរកន្លះនគរកម្ពុជា បានត្រូវពួកនេះសម្លាប់ ។ ពួកខ្មែរក្រហមដែដល់និងអ្នកដែលជួយឲ្យខ្មែរក្រហមឈ្នះ ច្បាប់កម្មផលនឹងកាត់ទោសពួកនេះ ក៏ដូចជាផ្លូវយុត្តិធម៌ក្នុងផ្លូវអាណាចក្រនឹងយកមេឃាតករនិងអ្នកដែលជួយឲ្យខ្មែរក្រហមឈ្នះ យកមកកាត់ទោសនៅពេលអនាគត ។៚